# សេវា ជា អប្បបរិមា

Service minimum

បើយើងតាមមើល សកម្មភាពនយោបាយ លោក សម-រង្ស៊ី និង កែម-សុខា នាបច្ចុប្បន្ននេះ យើងឃើញថាលោក ទាំងពីរ កំពុង ធ្វើការងារ ជាអប្បបរិមា តម្រូវតាម អនុសាសន៍ លោក ហ៊ុន-សែន។ សេវា នេះ មានកម្រិតវាច្បាស់លាស់ ឥតអាចបំពានបាន គឺៈ ទីវាល ភូមិសាស្ត្រ សេរីភាពក្នុងការនិយាយ និង **ភូមិនៃសកម្មភាព**[1] ដែលអនុញ្ញាតឲធ្វើបាន។

ជាពិសេស សកម្មភាពនេះ លោក ទាំងពីរ ដែលជា ទីងមោង ត្រូវតែធ្វើជាចាំបាច់ ដើម្បី លំអ ទូកញ្ចក់ របបនយោបាយ របស់ លោក ហ៊ុន-សែន ឲ សហគមអន្តរជាតិ គេមើលឃើញថា មានលទ្ធិប្រជាធិបតេយ្យ នៅស្រុកខ្មែរ។

**កំរិត ទីវាលភូមិសាស្ត្រ**ៈ អនុញ្ញាត ឲធ្វើបាន នៅតាម បណ្តាស្រុក ភូមិនានា តែហាមដាច់ខាត មិនឲមានធ្វើសកម្មភាព នៅទីក្រុងធំៗ ជាពិសេស នៅ រាជធានី ភ្នំពេញ ហើយជាពិសេសទៅទៀត គឺ នៅទីលាន ប្រជាធិបតេយ្យ។

**សេរីភាពក្នុងការនិយាយ**ៈ មិនអោយបាស់ពាល់ ដាច់ខាតដល់ លោក ហ៊ុន-សែន, រដ្ឋាភិបាល ជនអន្តោប្រវេសន៍យួន និង បញ្ហាព្រំដែន ជាមួយនឹង វៀតណាម។ តែអនុញ្ញាត ឲលើកមកឃោសានា អំពីកិច្ចការ បោះឆ្នោត ២០១៨ មក **ធ្វើវេទយិត**[2] មហាជន ដើម្បី បញ្ចុះក្នុង សតិ ពី ភាពស្របច្បាប់ នៃការបោះឆ្នោត សំរាប់អាណត្តិ ទី៦។

**ភូមិនៃសកម្មភាព**ៈ អាចមានសកម្មភាព បែបត្រឹមតែ ធ្វើកាយវិការ ឬ បង្គ្រប់កិច្ច អំពី ការប្រឆាំងនឹង អំពើពុករលួយ និង ការពារសិទ្ធិមនុស្ស ដែលជាប្រធានបទ ទូទៅ របស់ សកម្មជនក្នុងពិភពលោក ដើម្បី គ្រាន់តែចង់បង្ហាញថា រាជរដ្ឋាភិបាល មានឆន្ទះ ដោះស្រាយបញ្ហានេះ។

យើងឃើញថា សេវា ជាអប្បបរិមា នេះ ជាការ បម្រើ នយោបាយ គណបក្សកាន់អំណាច សុទ្ធសាត ជា សេវា ត្រូវធ្វើខានមិនបាន ព្រោះ លោកទាំងពីរនេះ បានទទួលកម្រៃ ពី លោក ហ៊ុន-សែន រួចទៅហើយ។ ក្រៅពី កម្រៃ ជា អាថ៌កំបាំង វាមានកម្រៃ ដែលគេមើលឃើញជាក់ស្តែង គឺ លោក សម-រង្ស៊ី ទទួលបាន អាសនៈ ជា តំណាងរាស្ត្រ មិនចាំបាច់បោះឆ្នោត ដែលលោក ហ៊ុន-សែន សុខចិត្តប្រគល់ឲ ឯចំណែក លោក កែម-សុខា បានទទួលងារ ជាអនុប្រធាន រដ្ឋសភា ដោយសារសម្លេងបោះឆ្នោតអោយ ពីសំណាក់ តំណាងរាស្ត្រ គណបក្សប្រជាជន តាមបញ្ញា

[1] ភូមិនៃសកម្មភាព=Domaine d’activité។
[2] ធ្វើវេទយិត= Sensibiliser។

លោក ហ៊ុន-សែន និង ព្យូរសិន ពីការចោទប្រកាន់ ពីតុលាការ អំពីបទធ្វើសកម្មភាព ប្រឆាំងនឹង សន្តិសុខរដ្ឋ។

តើ មោទនភាព លោក ទាំងពីរ មានដែរឬទេ លើឆាក អន្តរជាតិ ដែលតាំងខ្លួន ជាអ្នកប្រជាធិបតេយ្យនិយម ? ជា អ្នកដឹកនាំ ឆ្លាស់គ្នានឹង លោក ហ៊ុន-សែន ? ចរិតថោកទាប បែបនេះហើយ ដែលនាំឲ គេ វាយតម្លៃយ៉ាងទាបបំផុត ពី អ្នកនយោបាយខ្មែរ ហើយមានអ្នកខ្លះយល់ថែមទៀត បើ អ្នកដឹកនាំ គណបក្សប្រឆាំង មាន តម្លៃនយោបាយ ទាបបែបនឹង និង មានចរិតថោកទាប ផង ប្រហែលជាទុក លោក ហ៊ុន-សែន វាគ្រាន់បើជាង ព្រោះដូរយកមនុស្ស ដូចគ្នានឹង ហ៊ុន-សែន មកដឹកនាំជំនួស វាគ្មានប្រយោជន៍អ្វីនោះឡើយ។ ទស្សនៈនេះឯង ដែលមានកើតឡើង នៅពេលដែល មហាបាតុកម្មមហាជន ប្រឆាំងនឹង លទ្ធផលនៃការបោះឆ្នោតដែលទើបតែកន្លងមកនេះ គ្មានប្រសិទ្ធិភាព អ្វីសោះ។

លោក សម-រង្ស៊ី និង កែម-សុខា និង បរិវា មួយក្រុមតូច កំពុងរស់ ក្នុង អន្ទាក់មរណៈ ជួនប្រហែល រស់ជា ថៅកែនយោបាយ មានលុយក្រង្វក់ ជាសម្បត្តិសេដ្ឋីទុច្ចរិត បើគាត់ចេះដើរ **ទទីទទ័រ**[3] ទន្ទឹមគ្នា មិនឲដួល លើផ្លូវមរណៈ ដែល លោក ហ៊ុន-សែន គាត់ត្រាយឲដើរ, ជួនប្រហែល ជាអាច ទទួលទណ្ឌកម្មទាន់ហន់ ពីមាយាទថោកទាប របស់ខ្លួន។ តែជាអកុសលណាស់សំរាប់ ជាតិខ្មែរ ព្រោះគាត់នៅមាន អ្នកគាំទ្រផ្កាប់មុខ មើលឃើញថា សេវាអប្បបរិមា នេះ ជាសកម្មភាព សង្គ្រោះជាតិខ្មែរ។ សង្គ្រោះជាតិ បែបនេះ គឺពិត ជានាំគ្នា សង្គ្រោះយួន តាមបញ្ជាសម្ដេច ហ៊ុន-សែន នោះឯង។

ឧប សៅ សង្ហា

២៤ មករា ២០១៥

---

[3]ទទីទទ័រ= En tremblant។